

# រឿង កង្ហារយក្ស

Iem Tithseiha

Chan Pisey

Let's Read

The Asia Foundation



ថ្ងៃនេះសុភីមិនសប្បាយចិត្តដោយសាររឿង៣យ៉ាង។ សុភីស្អប់ធាតុអាកាស ដែលក្តៅស្អុះស្អាប់យ៉ាងខ្លាំង។



សុភីចង់ញ៉ាំផ្លែស្វាយ តែដើមស្វាយខ្ពស់ពេក។



សុភីចង់លេងជាមួយប្អូនប្រុសរបស់នាងឈ្មោះតក់។ សុភី៖ «តក់! តោះទៅរត់លេងជាមួយគ្នា។» តក់ប្រកែក៖ «ថ្ងៃនេះខ្ញុំមិនលេងទេព្រោះខ្លាចខូចសក់។» សុភីអន់ចិត្តនឹងតក់យ៉ាងខ្លាំង។



សុភីក៏ទៅអង្គុយនៅក្បែរកង្ហារចាស់តូចមួយ។ វាបក់យឺតៗ ហើយឮសំឡេង «ក្រឹកៗ» សុភីគិតម្នាក់ឯង៖ «សំឡេងនេះគួរឱ្យរំខានណាស់។»



ពេលនោះ សុភីឃើញបន្ទាត់មួយនៅក្បែរកង្ហារ។ សុភីក៏ចាប់កាន់វាឡើង។ សុភីក៏ចាប់ផ្ដើមវាស់៖ «ទំហំកង្ហារធំជាងបន្ទាត់នេះ២ដង»។ សុភីបើកភ្នែកធំៗ ហើយចាប់ផ្ដើមគិត។




«ទំហំកង្ហារប៉ុណ្ណឹង មានខ្យល់បក់ប៉ុណ្ណឹង។ ចុះបើកង្ហារធំជាង
នេះ ខ្យល់បក់ខ្លាំងជាងនេះដែរឬទេ?»



សុភីស្រែកឡើង៖ «នៅពេលនោះ កង្ហារនឹងមានខ្យល់បក់ «វូៗ» ដូចនៅមាត់ទន្លេដែរមែនទេ?» សុភីរំភើបចិត្តតែម្នាក់ឯង។ ហក់ផង លោតផងនៅពេញផ្ទះ។



សុភីគិតបណ្ដើរ សួរខ្លួនឯងបណ្ដើរ «ចុះបើកង្ហារធំប៉ុនផ្ទះ?» សុភីក៏យកបន្ទាត់វាស់ផ្ទះ។ សុភីវាស់ផ្ទះពីមុខដល់ក្រោយ និងពីឆ្វេងទៅស្ដាំ។



សុភីក៏ផ្ទុះសំណើចឮខ្លាំងៗ៖ «ហាស ហាស ហា! នៅពេលកង្ហារកាន់តែធំ ខ្យល់ក៏បក់កាន់តែខ្លាំង។ នៅពេលនោះផ្លែស្វាយនឹងហើរចេញពីដើមស្វាយ។» អាកូនឆ្កែបូបូ! ឯងច្បាស់ជាហើរតាមខ្យល់ ព្រោះឯងស្រាលជាងខ្ញុំ។ ចុះតក់? សក់របស់គេ នឹងបះធំឡើងដូចសំបុកមាន់មិនខាន។



ស្រាប់តែសុភីភ្ញាក់ព្រឺត នឹងសំឡេងរបស់តក់។ តក់៖ «បងសុភី! នេះផ្លែស្វាយ។» សុភីសប្បាយចិត្តយ៉ាងខ្លាំង ព្រោះនាងបានញ៉ាំផ្លែស្វាយ។ សុភីក៏ប្រាប់តក់អំពីរឿងបន្ទាត់និងកង្វារ។




តក់ចាប់កាន់បន្ទាត់ឡើង ហើយសួរសុភី៖ «ចុះបើទំហំកង្ហារធំជាង១លានដង?»



សុភីក៏ឆ្លើយ៖ «អស្ចារ្យណាស់! ពេលនោះ នៅលើផែនដីយើងនឹងមានកង្ហាររយក្ស។ នៅពេលយើងចុចបើកកង្ហារពេលណា ចាន ឆ្នាំង តុ កៅអី កាតាប សៀវភៅ ផ្ទះ អគារធំៗ និងដើមស្វាយ នឹងហើរមិនខានឡើយ។»



សំឡេងកូនឆ្កែព្រុស«វ៉ូសៗ» ធ្វើឱ្យគេទាំងពីរនាក់ភ្ញាក់ខ្លួនពីការស្រមើស្រមៃ។ តក់ និងសុភីអង្គុយនៅជិតកូនកង្ហារចាស់។ ពួកគេញាំផ្លែស្វាយជាមួយគ្នា ហើយសើចឮៗ។



ពួកគេក៏លេងសប្បាយជាមួយគ្នា។ សុភីនិយាយ៖ តក់!
ថ្ងៃណាមួយ យើងនឹងផលិតកង្ហារយក្សនោះជាមួយគ្នា។ តក់៖
ពិតមែនហើយ! បងជាអ្នកផលិតកង្ហារ ហើយខ្ញុំចាំញ៉ាំផ្លែស្វាយ
ដែលជ្រុះធ្លាក់ពីដើមស្វាយ។

**រឿង កង្ហារយក្ស**

សមាជិកក្រុមហាក់កាថុន៖ **អៀម ទិត្យសីហា** (អ្នកនិពន្ធ) **ចាន់ ពិសី** (វិចិត្រករ) **អ៊ុង គាមេសា** (អ្នករចនា)

សូមថ្លែងអំណរគុណជាពិសេសដល់ ហ៊ុយ ឆេងរតនា សឿម កក្កដា ជូ ជីនិត ហួត សុជាតា និងក្រុមការងារ **CamAnt Technology** ចំពោះការជួយគាំទ្រដល់កម្មវិធីហាក់កាថុនសៀវភៅអេឡិចត្រូនិចតោះអាន! ដែលបានធ្វើឡើងក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ និង ២០ ខែ កញ្ញា ឆ្នាំ ២០១៧។

© មូលនិធិអាស៊ី ឆ្នាំ ២០១៧។ រក្សាសិទ្ធិមួយចំនួន។ ស្នាដៃនេះស្ថិតក្រោមអាជ្ញាប័ណ្ណ **Creative Commons Attribution-NonCommercial 4.0 (https://creativecommons.org/licenses/by-nc/**4.0/)។ អ្នកអាចចែករំលែក (ថតចម្លង ចែកចាយបន្តឯកសារនេះ ដោយមធ្យោបាយ ឬទម្រង់អ្វីក៏បាន) ដោយសេរី និងធ្វើការកែសម្រួល (លាយបញ្ចូលជាមួយខ្លឹមសារផ្សេងទៀត បម្លែង និងបង្កើតជាឯកសារផ្សេងទៀត) ស្នាដៃនេះ សម្រាប់គោលបំណងមិនមែនពាណិជ្ជកម្ម។ អ្នកចេញអាជ្ញាប័ណ្ណមិនអាចដកហូតសេរីភាពទាំងនេះបានឡើយ ដរាបណាអ្នកគោរពទៅតាមលក្ខខណ្ឌនៃ អាជ្ញាប័ណ្ណ ដូចខាងក្រោម៖

សេចក្តីថ្លែងអំណរគុណ - អ្នកត្រូវសរសេរពីប្រភពឯកសារឲ្យបានសមស្រប បង្ហាញពីតំណភ្ជាប់ទៅកាន់អាជ្ញាប័ណ្ណ និងបញ្ជាក់ពីការផ្លាស់ប្តូរខ្លឹមសារ ប្រសិនបើមាន។
អ្នកអាចធ្វើបែបនេះ តាមវិធីណាក៏បានដែលសមស្រប ប៉ុន្តែពុំមានន័យថា អ្នកផ្តល់អាជ្ញាប័ណ្ណគាំទ្រដល់អ្នក ឬដល់ការប្រើប្រាស់របស់អ្នកនោះទេ។
មិនមែនលក្ខណៈពាណិជ្ជកម្ម - អ្នកមិនអាចប្រើប្រាស់ឯកសារនេះ សម្រាប់គោលបំណងពាណិជ្ជកម្មឡើយ។

**Giant Fan**

Hackathon team: **Iem Tithseiha** (Writer), **Chan Pisey** (Illustrator), **Ong Keamesa** (Graphic Designer)

Special thanks to Huy Chheng Rattana, Soeurm Kakada, Chou Chinith, Socheata Huot, and the CamAnt Technology team for their help with the Let's Read! E-Book Hackathon, which took place in Phnom Penh on 19 and 20 August 2017.

© The Asia Foundation, 2017. Some rights reserved. This work is licensed under a Creative Commons Attribution-NonCommercial 4.0 Licence (https://creativecommons.org/licenses/by-nc/4.0/). You are free to share (copy and redistribute the material in any medium or format) and adapt (remix, transform, and build upon the material) this work for any non-commerical purpose. The licensor cannot revoke these freedoms as long as you follow the following license terms:

Attribution — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.
NonCommercial — You may not use the material for commercial purposes.

Generously supported by

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*រឿង កង្ហារយក្ស (The Giant Fan)*, Author: Iem Tithseiha. Illustrator: Chan Pisey. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/